**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៧...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១០ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីមុខងារនិងភារកិច្ច ព្រមទាំងការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរកាត់ថា "គ.ប.ក.គ" និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរកាត់ថា "អ.ក.គ" ដើម្បីគាំទ្រដល់ការបំពេញមុខងារ របស់ក្រុមប្រឹក្សាជាតិគាំពារសង្គមឲ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ប.ក.គ និង អ.ក.គ។

## ជំពូកទី២
## ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ប.ក.គ

### ផ្នែកទី១
### សមាសភាព

**មាត្រា ៣.-**

គ.ប.ក.គ មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១ រូប | ប្រធាន |
| ២- | រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១ រូប | អនុប្រធាន |
| ៣- | រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ រូប | អនុប្រធាន |
| ៤- | រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ១ រូប | អនុប្រធាន |
| ៥- | អគ្គលេខាធិការនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | អនុប្រធាន |
| ៦- | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| ៧- | តំណាងក្រសួងមហាផ្ទៃ ១ រូប | សមាជិក |
| ៨- | តំណាងក្រសួងការពារជាតិ ១ រូប | សមាជិក |
| ៩- | តំណាងក្រសួងផែនការ ១ រូប | សមាជិក |
| ១០- | តំណាងក្រសួងយុត្តិធម៌ ១ រូប | សមាជិក |

| | | |
|---|---|---|
| ១១- | តំណាងក្រសួងកិច្ចការនារី ១ រូប | សមាជិក |
| ១២- | តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប | សមាជិក |
| ១៣- | តំណាងក្រសួងមុខងារសាធារណៈ ១ រូប | សមាជិក |
| ១៤- | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៥- | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៦- | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៧- | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨- | អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិកអចិន្ត្រៃយ៍ |

គ.ប.ក.គ អាចមានសមាសភាពបន្ថែមតាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃ គ.ប.ក.គ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម បំពេញមុខងារជាលេខាធិការនៃ គ.ប.ក.គ។

## ផ្នែកទី២

## តួនាទី និងភារកិច្ច

**មាត្រា ៤** .-

គ.ប.ក.គ ជាយន្តការសម្របសម្រួលរវាងកម្រិតគោលនយោបាយនិងកម្រិតបច្ចេកទេស សម្រាប់គាំទ្រពល់ការបំពេញមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម។

គ.ប.ក.គ មានភារកិច្ចសម្របសម្រួល តាមដាន និងត្រួតពិនិត្យ ការអនុវត្តគោលនយោបាយនិងផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងការងារគាំពារសង្គម ដើម្បីរាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម

គ.ប.ក.គ អាចស្នើសុំប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម កោះប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម តាមការចាំបាច់។

**មាត្រា ៥** .-

គ.ប.ក.គ អាចស្នើសុំក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារបច្ចេកទេសស្របតាមតម្រូវការនៃការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម នៅក្នុងប្រព័ន្ធគាំពារសង្គម។

អនុគណៈកម្មាធិការ ក្រុមការងារបច្ចេកទេស និងក្រសួង-ស្ថាប័នទាំងឡាយដែលមានសកម្មភាព ឬប្រតិបត្តិការគាំពារសង្គម ត្រូវផ្តល់របាយការណ៍ជាប្រចាំជូន គ.ប.ក.គ អំពីការបំពេញការងាររបស់ខ្លួន។

បែបបទ និងទម្រង់នៃរបាយការណ៍ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា ៦ .-**

គ.ប.ក.គ មានភារកិច្ចសម្របសម្រួល និងជាសេនាធិការជូនក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីកៀគរធនធានហិរញ្ញវត្ថុ និងកសាងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិក្នុងវិស័យគាំពារសង្គម។

ផ្នែកទី៣

ការប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ

**មាត្រា ៧ .-**

អនុប្រធាន និងសមាជិកនៃ គ.ប.ក.គ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមាន។

គ.ប.ក.គ អាចអញ្ជើញប្រធានអនុគណៈកម្មាធិការ ប្រធានក្រុមការងារបច្ចេកទេស ឬតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា តំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ដើម្បីពិភាក្សាការងារក្នុងគោលដៅជំរុញវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម តាមការចាំបាច់។

**មាត្រា ៨.-**

ប្រធាន គ.ប.ក.គ ក្នុងនាមជាសេនាធិការដឹកនាំ ត្រូវចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងនាមជាអ្នកផ្តល់យោបល់។ ក្នុងករណីអវត្តមាន ប្រធាន គ.ប.ក.គ ត្រូវផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីចូលរួមប្រជុំជំនួស។

**ជំពូកទី៣**

**ការបង្កើតអគ្គលេខាធិការដ្ឋាន**

ផ្នែកទី១

ការបង្កើតអគ្គលេខាធិការដ្ឋាន

**មាត្រា ៩.-**

ត្រូវបានបង្កើត អគ្គលេខាធិការដ្ឋានៃក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការបច្ចេកទេសសម្រាប់ក្រុមប្រឹក្សាជាតិគាំពារសង្គម និង គណៈកម្មាធិការប្រតិបត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ផ្នែកទី២

## រចនាសម្ព័ន្ធ មុខងារ និងភារកិច្ច

**មាត្រា ១០.** -

អ.ក.គ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម៖

១. នាយកដ្ឋានជំនួយសង្គម មាន មុខងារ និងភារកិច្ចជួយ អ.ក.គ លើការងារជំនួយសង្គម

២. នាយកដ្ឋានសន្តិសុខសង្គម មានមុខងារ និង ភារកិច្ចជួយ អ.ក.គ លើការងារសន្តិសុខសង្គម

៣. នាយកដ្ឋាននីតិកម្ម មានមុខងារ និងភារកិច្ចជួយ អ.ក.គ លើការងារនីតិកម្ម និង

៤. នាយកដ្ឋានកិច្ចការទូទៅ មានមុខងារ និងភារកិច្ចជួយ អ.ក.គ លើការងារទូទៅ។

នាយកដ្ឋាននីមួយៗនៃ អ.ក.គ ដឹកនាំដោយប្រធាន ១ រូប និងមានអនុប្រធានមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មុខងារ និងភារកិច្ចលម្អិតនៃនាយកដ្ឋានក្រោមចំណុះអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ជ.គ.ស។

## ផ្នែកទី៣

## មន្ត្រី និងបុគ្គលិក

**មាត្រា ១១.** -

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការ ១ រូប និងមានអគ្គលេខាធិការរងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការ ត្រូវតែងតាំង និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

អគ្គលេខាធិការរង ត្រូវតែងតាំង និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា ១២.** -

អ.ក.គ អាចស្នើជ្រើសរើសមន្ត្រីមុខងារសាធារណៈ ឲ្យបម្រើការងារនៅក្នុង អ.ក.គ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមនីតិវិធីជាធរមាន។

អ.ក.គ អាចជ្រើសរើសមន្ត្រីរាជការមុខងារសាធារណៈមកបម្រើការនៅ អ.ក.គ ពីក្រសួង ស្ថាប័នដទៃ ដោយមានការឯកភាពពីប្រធានស្ថាប័នសាមី។ មន្ត្រីទាំងនោះ ត្រូវដាក់ឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម និងបំពេញការងារពេញម៉ោងនៅ អ.ក.គ លើកលែងតែអគ្គលេខាធិការ។

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឲ្យបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវរក្សាទុកប្រាក់បៀវត្ស ប្រាក់វិភាជន៍គ្រួសារ និងអតីតភាពការងារនៅអង្គភាពដើមក្នុងពេលបំពេញការងារនៅ អ.ក.គ។

ក្រោយពេលបញ្ចប់ពីមុខតំណែងក្នុង អ.ក.គ មន្ត្រីសាមីត្រូវដាក់ពាក្យសុំចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ ដោយផ្តល់ជូនជាស្វ័យប្រវត្តិនូវឋានន្តរសក្តិ និងថ្នាក់អនុលោមតាមកឋាខ័ណ្ឌខាងលើ ព្រមទាំងប្រាក់បំណាច់មុខងារផ្អែកលើមុខតំណែងក្នុងមុខងារសាធារណៈ ដែលមានមុនពេលការតែងតាំងចូលបម្រើការងារក្នុង អ.ក.គ។ មន្ត្រីសាមីនឹងទទួលបានសិទ្ធិអាទិភាពក្នុងការតែងតាំងក្នុងមុខតំណែងដើម ឬមុខតំណែងទំនេរ ប្រហាក់ប្រហែលនឹងមុខតំណែងដើម ផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន និងការសម្រេចរបស់ប្រធានស្ថាប័ន។

បុព្វលាភ និងប្រាក់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំ និងមន្ត្រីដែលបម្រើការងារនៅ អ.ក.គ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ១៣.** -

ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អ.ក.គ អាចជ្រើសរើសទីប្រឹក្សា អ្នកជំនាញការជាតិ ឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យា ដើម្បីជួយការងារ ស្របតាមនីតិវិធីជាធរមាន។

## ផ្នែកទី៤

## ថវិកា

**មាត្រា ១៤.** -

អ.ក.គ មានកញ្ចប់ថវិកាដោយឡែកសម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម គ.ប.ក.គ និង អ.ក.គ ផ្ទាល់។ ថវិការបស់ អ.ក.គ អាចមានប្រភពមកពី៖

- ថវិការដ្ឋដែលស្ថិតនៅក្រោមកញ្ចប់ថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង
- ប្រភពស្របច្បាប់ផ្សេងៗទៀត។

ថវិការបស់ អ.ក.គ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើ របស់អគ្គលេខាធិការ តាមរយៈប្រធាន គ.ប.ក.គ។

## ផ្នែកទី៥

## សវនកម្ម

**មាត្រា ១៥.** -

អ.ក.គ ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច និងសវនកម្ម ស្របតាមច្បាប់ជាធរមាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៦.** -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៧.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្ដេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៨

## អង្គភាពលេខរបស់
## អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម



## ផែនការសកម្មភាពអាទិភាពសម្រាប់អតិទឡ្ហន៍ប្រព័ន្ធគាំពារសង្គមឆ្នាំ២០១៨

| [illegible] | [illegible] | ផែនការសកម្មភាព | [illegible] | [illegible] |
|---|---|---|---|---|
| ក. | ប្រព័ន្ធជំនួយសង្គម | | | |
| ក.១ | កម្មវិធីផ្តល់អាហារតាមសាលារៀន | វាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធី និងកំណត់ទិសដៅអនាគត | ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| ក.២ | កម្មវិធីអាហារូបករណ៍ជាសាច់ប្រាក់ | វាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធី និងកំណត់ទិសដៅអនាគត | | |
| ក.៣ | កម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារ | សិក្សា និងរៀបចំម៉ូដែលសម្រាប់កម្មវិធីថ្នាក់ជាតិ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អង្គការ UNICEF |
| ក.៤ | កម្មវិធីឧបត្ថម្ភជនចាស់ជរា | សិក្សាសមិទ្ធិលទ្ធភាពក្នុងការដាក់ឲ្យអនុវត្តកម្មវិធីក្នុងលក្ខណៈជាកញ្ចប់គ្រួសារ | | |
| ក.៥ | កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ | កែសម្រួលយន្តការកំណត់អត្តសញ្ញាណជនពិការ | | |
| ខ. | ប្រព័ន្ធសន្តិសុខសង្គម | | | |
| ខ.១ | ការថែទាំសុខភាព | រៀបចំដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ ILO |
| | | សិក្សាសមិទ្ធិលទ្ធភាពស្តីពីការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់ពលរដ្ឋនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ក្រសួងសុខាភិបាល | អង្គការ JICA |
| ខ.២ | សោធន | បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីសិក្សាលើជម្រើសសម្រាប់ការកែទម្រង់របបសោធនសម្រាប់មន្ត្រីសាធារណៈ និងដើម្បីដាក់ឲ្យដំណើរការរបបសោធនសម្រាប់កម្មករនិយោជិតនៅឆ្នាំ២០១៩ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ AFD និង ILO |
| គ. | អភិបាលកិច្ច | | | |

| | | | | |
|---|---|---|---|---|
| គ.១ | កម្រិតគោលនយោបាយ | រៀបចំបង្កើត និងដាក់ឲ្យដំណើរការគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | | រៀបចំបង្កើត និងដាក់ឲ្យដំណើរការអនុគណៈកម្មាធិការជំនួយសង្គម | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | |
| | | រៀបចំបង្កើត និងដាក់ឲ្យដំណើរការអនុគណៈកម្មាធិការសន្តិសុខសង្គម | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| គ.២ | កម្រិតបញ្ញត្តិករ | សិក្សាអំពីម៉ូដែលសម្រាប់ការធ្វើសមាហរណកម្មបញ្ញត្តិករវិស័យហិរញ្ញវត្ថុមិនមែនធនាគារ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| គ.៣ | កម្រិតប្រតិបត្តិករ | រៀបចំផែនការសម្រាប់ការធ្វើសមាហរណកម្មស្ថាប័នប្រតិបត្តិករសន្តិសុខសង្គមដែលមានស្រាប់ (ប.ជ.ស ប.ស.ស ប.ជ.អ និង ម.ជ.ព) ឲ្យទៅជាស្ថាប័នតែមួយ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | |
| | | សិក្សាអំពីលទ្ធភាពក្នុងការបង្កើតប្រតិបត្តិករជំនួយសង្គមរួម | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | |
| ឃ. | បញ្ហាឆ្លងវិស័យ | | | |
| ឃ.១ | ប្រព័ន្ធចុះបញ្ជី | សិក្សាអំពីលទ្ធភាពក្នុងការតភ្ជាប់ ឬធ្វើសមាហរណកម្មប្រព័ន្ធចុះបញ្ជី និងប្រព័ន្ធ IT ដែលពាក់ព័ន្ធនឹងប្រតិបត្តិករគាំពារសង្គម | អគ្គលេខាធិការដ្ឋាន | អង្គការ GIZ និង USAID |
| ឃ.២ | ការអប់រំ | រៀបចំសិក្ខាសាលាលើកកម្ពស់ចំណេះដឹងសាធារណជនស្តីពីការគាំពារសង្គម | អគ្គលេខាធិការដ្ឋាន | |
| | | រៀបចំកម្មវិធីទូរទស្សន៍ដើម្បីលើកកម្ពស់ចំណេះដឹងសាធារណជនស្តីពីការគាំពារសង្គម | អគ្គលេខាធិការដ្ឋាន | |
| ឃ.៣ | ការវិនិយោគ | សិក្សារៀបចំយន្តការគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម | អគ្គលេខាធិការដ្ឋាន និង ប.ស.ស | អង្គការ ILO |
| ឃ.៤ | ច្បាប់ និងបទប្បញ្ញត្តិ | រៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម | អគ្គលេខាធិការដ្ឋាន | អង្គការ GIZ |